ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៦៧/២៤ រ.បក.

# របាយការណ៍
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# ប្រចាំខែកុម្ភៈ និងទិសដៅខែមីនា ឆ្នាំ២០២៤

## I. ស្ថានភាពទូទៅ

សភាពការណ៍សកលលោកបានប្រឈមនឹងវិបត្តិសាកលធំៗ ប្លែកៗ គួរឱ្យកត់សម្គាល់ រួមទាំងគ្រោះធម្មជាតិពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ជម្ងឺរាតត្បាត វិបត្តិខ្វះស្បៀងអាហារ សង្គ្រាមរ៉ាំរ៉ៃដែលបាន និងកំពុងគម្រាមកំហែងដល់សន្តិសុខមនុស្សជាតិ តាមបណ្តាប្រទេសដែលមានខឿនឧស្សាហកម្មជឿនលឿនមួយចំនួន បានជះឥទ្ធិពលជាអវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គមជាសកល គួរឱ្យព្រួយបារម្ភ ដែលវិបត្តិនេះ ក៏បានជះឥទ្ធិពលដល់បណ្តាប្រទេសនានា រួមទាំងកម្ពុជាផងដែរ។ ក្នុងស្ថានភាពដ៏លំបាកនេះ ប្រជាពលរដ្ឋ តាមបណ្តាប្រទេសនានាបានប្រឈមនឹងកង្វល់យ៉ាងធ្ងន់ធ្ងរនៃអសន្តិសុខ ក៏ដូចជាភាពស្មុគ្រស្មាញក្នុងជីវភាពរស់នៅ ដែលជាឱកាសឱ្យក្រុមទុច្ចរិតបានប្រើគ្រប់មធ្យោបាយទាញយកផលចំណេញ តាមរយៈការបង្កើតនូវបទល្មើសថ្មីៗ រួមទាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ ជាពិសេស ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដ៏ទំនើប ទាក់ទាញមនុស្សគ្រប់វ័យ គ្រប់ភេទ គ្រប់ស្ថានភាព ឱ្យរងគ្រោះ ក្នុងកលល្បិចដ៏ពិសពុលដើម្បីបម្រើមហិច្ឆតាផលប្រយោជន៍ទុច្ចរិតរបស់ខ្លួនយ៉ាងសាហាវឃោរឃៅ។

ឆ្លៀតក្នុងស្ថានភាពដ៏ប្រឈមនេះ ក្រុមទុច្ចរិត និងបណ្តាញរបស់ខ្លួន បានព្យាយាមរកគ្រប់មធ្យោបាយបង្កើតនូវបទល្មើសថ្មីៗ នៃទាសភាពសម័យទំនើប និងលេចឡើងនូវការកេងប្រវ័ញ្ច និងរំលោភបំពានតាមប្រព័ន្ធអនឡាញ ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប ទាក់ទាញជនរងគ្រោះ ឱ្យធ្លាក់ចូលក្នុងកលល្បិចទុច្ចរិត ដើម្បីបម្រើមហិច្ឆតារបស់ខ្លួន ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងធំធេងលើជនរងគ្រោះ និងជនងាយរងគ្រោះ។

ដោយឡែក នៅប្រទេសកម្ពុជា ឆ្នាំ២០២៣ គឺជាពេលវេលានៃការបោះឆ្នោតជាសកល ដើម្បីរៀបចំរាជរដ្ឋាភិបាលថ្មី នីតិកាលទី៧នៃរដ្ឋសភា។ រាជរដ្ឋាភិបាលថ្មីនេះ បានបន្តការប្តេជ្ញាចិត្ត យកចិត្តទុកដាក់យ៉ាងខ្លាំងលើកិច្ចការពារថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ សុខសុវត្ថិភាពនិងសុខុមាលភាពសង្គមឱ្យបានរឹងមាំ ព្រមទាំងការធានានូវសិទ្ធិសេរីភាពគ្រប់យ៉ាងរបស់ពលរដ្ឋ ដោយផ្អែកលើរដ្ឋធម្មនុញ្ញនិងបទបញ្ញត្តិច្បាប់ជាធរមាន។ ឯនៅក្នុងតំបន់ ខិតខំដោះស្រាយបញ្ហា ដោយទន់ភ្លន់បញ្ចៀសការប្រឈមមុខដាក់គ្នា និងការពារភាពរឹងមាំនៃចំណងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ។

ជាការឆ្លើយតបចំពោះការប្តេជ្ញាចិត្តខ្ពស់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជរដ្ឋាភិបាលអណត្តិថ្មីបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ មុំទី១ (ការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ - អទិភាពទី៤) និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។ ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាសេនាធិការ ជូនរាជរដ្ឋាភិបាល ក៏បានការកែ

សម្រួលរចនាសម្ព័ន្ធរបស់ខ្លួនផងដែរចាប់ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ និងរៀបចំផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ(២០២៤-២០២៨)។

ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងខាងលើ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ បានធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការ ដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

**១. ការកសាងច្បាប់**

- ក្រសួងយុត្តិធម៌ បានរៀបចំបន្តពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី «អំពើពពោះជំនួស» និងច្បាប់ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស»។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។

២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «បត្យាប័ន» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការផ្ទេរទណ្ឌិត» ជាមួយសាធារណរដ្ឋប៉េរូ សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋតួកគី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងព្រះរាជាណាចក្របែលហ្ស៊ិក។

### ខ. ការបង្ការ ទប់ស្កាត់

**១. តាមរយៈការលើកកម្ពស់ការយល់ដឹង**

**១.១. ការអប់រំដោយផ្ទាល់**

១.១.១. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

នៅក្នុងកុម្ភៈ ឆ្នាំ២០២៤នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ សរុបចំនួន ១៤.៥១៦លើក មានអ្នកចូលរួមសរុបចំនួន ៧៩៤.៣៣៦នាក់ (ធៀបនឹងខែមករាចំនួន ៧៣៤.៩៨០នាក់ គឺមានកើនឡើងចំនួន ៥៩.៣៥៦នាក់ ស្មើនឹង ៧,៤៧% ក្នុងនោះស្ត្រីចំនួន ៤២៣.២៥២នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

## តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៩៧៧ | ៨៦.៤៥៣ | ៤៥.១០៧ | ២៩០ | ១៦.៨៣០ | ៨.៦៣៣ |
| សរុប ក្រសួង ស្ថាប័ន | | ៩៧៧លើក | ៨៦.៤៥៣នាក់ | ៤៥.១០៧នាក់ | ២៩០លើក | ១៦.៨៣០នាក់ | ៨.៦៣៣នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | ១៧ | ៦.៩៩៩ | ៣.៤៩៧ |
| ២ | ខេត្តកណ្ដាល | ១.៥៥៤ | ១១៤.០២៣ | ៥៧.១២៨ | ១.៤៤៥ | ៥២.៣៣៩ | ២៧.៣៨២ |
| ៣ | ខេត្តបាត់ដំបង | ៩៤៥ | ៤៦.៥៤១ | ២៣.៨៥០ | ៧៥៥ | ២៦.០៣៥ | ១៤.៨៨៤ |
| ៤ | ខេត្តពោធិ៍សាត់ | ៣៣១ | ២៦.០២១ | ១១.៨៩៥ | ១៧៩ | ៦.៨០២ | ៣.០៥២ |
| ៥ | ខេត្តសៀមរាប | ៥៤៨ | ៣៩.៨៤០ | ២៣.៥២៦ | ១៣១ | ៤.០៧៣ | ២.៥០៥ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៦៩១ | ២០.៤១៥ | ១០.៥០៨ | ៣៤៧ | ១០.៦២៥ | ៥.៦៥៧ |
| ៧ | ខេត្តកំពង់ចាម | ១.៨០៥ | ១០៤.៨៧០ | ៥៤.៤៦៨ | | | |
| ៨ | ខេត្តព្រះសីហនុ | ១០១ | ៦.២៨៤ | ៣.១៧២ | ៤ | ២៦២ | ១៥៥ |
| ៩ | ខេត្តព្រះវិហារ | | | | | | |
| ១០ | ខេត្តស្វាយរៀង | ២៨៣ | ១៣.២៨៨ | ៧៣៥០ | ២៨៨ | ៩.២៧៧ | ៥.៧៩៧ |
| ១១ | ខេត្តប៉ៃលិន | ៥ | ៨៦៨ | ៣៧៦ | ១២៧ | ៤.៦២៥ | ១.៥០៤ |
| ១២ | ខេត្តកោះកុង | ៣២៧ | ៩.៥៨២ | ៤.៨២៤ | ១៤៨ | ៣.៧៥១ | ១.៤៦៧ |
| ១៣ | ខេត្តកំពត | ៧៥ | ១.៣៦៦ | ៨៣៧ | | | |
| ១៤ | ខេត្តកំពង់ធំ | ៣២ | ១៩.៤១៧ | ១៩.៤៤៩ | ៩៨ | ៦.១៥៧ | ៣.៤៣៦ |
| ១៥ | ខេត្តតាកែវ | ៤៩៨ | ២៣.២០២ | ១០.៥៣៨ | ១១៣ | ៣.៨៤៩ | ២.២២១ |
| ១៦ | ខេត្តក្រចេះ | ១២ | ៥០៧ | ២៣០ | | | |
| ១៧ | ខេត្តកែប | ៣០ | ៥.៥៧៨ | ៣.១៨៤ | ៥៤ | ២.៣៧៧ | ១.២៧៨ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | ៥៨០ | ៧០.៣៦០ | ៣៥.៦២៣ | ១៥០ | ៥.២៧០ | ២.៧៥៣ |
| ២២ | ខេត្តត្បូងឃ្មុំ | ១០៥ | ៣.២៧១ | ១.៧៨៥ | ៣ | ១៣៧ | ៤៣ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៨១១ | ១២.៦០៣ | ៧.៣០៧ | ១៩៩ | ៥.៧១០ | ៣.៣៨៧ |
| ២៤ | ខេត្តឧត្ដរមានជ័យ | ៤១១ | ២២.៨៣៩ | ១៣.២៧៦ | ៤៧ | ១.៨៩០ | ១.១៦៨ |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| សរុប រាជធានី-ខេត្ត | | ៩.១៤៤លើក | ៥៤០.៨៧៥នាក់ | ២៨៩.៣២៦នាក់ | ៤.១០៥លើក | ១៥០.១៧៨នាក់ | ៨០.១៨៦នាក់ |
| សរុបរួម | | ១៤.៥១៦ លើក | | ៧៩៤.៣៣៦ នាក់ | | ៤២៣.២៥២ នាក់ | |

### ១.១.២. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

• លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីក្នុងកម្មវិធីផ្សព្វផ្សាយយុទ្ធនាការ "តើអ្នកអាចឃើញខ្ញុំទេ? Can you see me?" ដែលរៀបចំឡើងនៅរោងភាពយន្តលេជេនផ្សារទំនើបហេរីថេករ៉ែក ក្រុងសៀមរាប ដោយអង្គការមូលនិធិអេ២១ តាមរយៈកិច្ចសហការក្នុងភាពជាដៃគូជាមួយ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរដ្ឋបាលខេត្តសៀមរាប សរុបអ្នកចូលរួមទស្សនា ចំនួន ១៧៥នាក់ (ស្រី ១១៦នាក់)។

### ១.១.៣. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

- **ខេត្តបន្ទាយមានជ័យ៖**
    - មជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ បានធ្វើការផ្សព្វផ្សាយដល់សហគមន៍ ស្តីពីការ ធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពចំនួន ៣៤លើក មនុស្សចំនួន ១.៥៩៥នាក់ (ស្រី ១.០៨៦នាក់) យុវជន ៤១០នាក់ (ស្រី ២២៩នាក់) អតីតពលករ ៣៧៨នាក់ (ស្រី ២៥១នាក់)។
    - អង្គការតំណក់ទឹក បានចុះធ្វើសកម្មភាពបណ្ណាល័យចល័ត អប់រំដល់ក្រុមយុវជន និងគ្រួសារ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពចំនួន ១៦៦នាក់ (ស្រី ៨៣នាក់)។
    - អង្គការសាម៉ារីតាន់ភឺស បានអប់រំសហគមន៍អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករចំនួន ៧៥០នាក់ (ស្រី ២២៦នាក់) កុមារ ៤៨នាក់ (កុមារី ៣៥នាក់)។
    - អង្គការ IOM បានធ្វើការផ្តល់វគ្គតម្រង់ទិស ស្តីពីធ្វើការសម្រេចចិត្តដែលប្រកបដោយសុវត្ថិភាព ដល់ពលករសុរប ៣៤០នាក់ ស្រី១៣០នាក់ កុមារ៣២នាក់។

### ១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ផ្សព្វផ្សាយតាមរយៈផេកហ្វេសប៊ុក មានអ្នកចូលទស្សនាចំនួន ១.២៥០ដង។
- **ខេត្តត្បូងឃ្មុំ៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុជាតិ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន ៤០លើក។
- **ខេត្តសៀមរាប៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយតាមនៅវិធីវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិ ស្តីពីកិច្ចការពារជនរងគ្រោះ វិធានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការស្វែងរកការងារធ្វើក្នុងស្រុកជាជាងការចំណាកដោយប្រថុយប្រថាន ការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិលចំនួន ២៣៩លើក។
- **ខេត្តព្រៃវែង៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយសារអប់រំតាមវិទ្យុបារាយណ៍អណ្តែត ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន ៥០លើក។
- **ខេត្តប៉ៃលិន៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន ២៤៨លើក។

### ១.៣. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

- **ខេត្តកំពង់ចាម** តំណាងស្នងការនគរបាលខេត្តបានចូលរួមជាវាគ្មិន៖ ១-ស្តីពីការទប់ស្កាត់ភាពមិនប្រក្រតី របស់យុវជនក្នុងទិវាបុណ្យនៃក្តីស្រឡាញ់។ ២-ប្រសិទ្ធភាពនៃការទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់។
- **ខេត្តព្រៃវែង៖** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើបទបង្ហាញចែករំលែកចំណេះដឹង និងបទពិសោធន៍ ស្តីពីស្ថានភាពទូទៅនៃការធ្វើចំណាកស្រុករបស់ពលករទេសន្តរប្រវេសន៍ និងយន្តការនៃការដាក់ពាក្យបណ្តឹង ដែលមានអ្នកចូលរួមចំនួន ៦០នាក់ (ស្រី ២៩នាក់)។

### ១.៤. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- **ខេត្តបន្ទាយមានជ័យ៖**
  - លេខាធិការដ្ឋាន គ.ខ.ប.ជ បានចងបដាពាក្យស្លោកទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០៦ផ្ទាំង នៅសួនសាធារណៈ(សួនតេជោឈ្នះៗខេត្តបន្ទាយមានជ័យ)។
  - អង្គការសាម៉ារីតាន់ភឺស បានផ្ដល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃ ចំនួន៧០៥នាក់ (ស្រី ២៦៦នាក់ កុមារី ៣១នាក់)។

- **ខេត្តបាត់ដំបង៖** អង្គការសាម៉ារីតាន់ភឺស បានចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ៣០៧សន្លឹក ខិត្តប័ណ្ណទប់ស្កាត់ការជួញដូរមនុស្ស ២៧៦សន្លឹក និងខិត្តប័ណ្ណអប់រំពីការពារការរំលោភបំពានកុមារ តាមប្រព័ន្ធអនឡាញចំនួន ១៨៦សន្លឹក។

- **ខេត្តសៀមរាប៖** រដ្ឋបាលស្រុកពួក បានធ្វើការចែកខិតប័ណ្ណព័ត៌មាន ស្ដីពីការធ្វើចំណាកស្រុក និងការស្វែងរកជំនួយចំនួន ៣.៤៦១ខិតប័ណ្ណ។

- **ខេត្តតាកែវ៖** មន្ទីរអប់រំ យុវជន និងកីឡាខេត្ត សហការជាមួយអាជ្ញាធរ អង្គការដៃគូ បានផ្សព្វផ្សាយអប់រំ តាមរយៈពាក្យស្លោក ស្ដីពីអំពើហិង្សា ការជួញដូរផ្លូវភេទកុមារចំនួន ១៤០សន្លឹក ស្មើ ៥០សាលា និងតាមថ្នាក់ចំនួន ២៥០ពាក្យស្លោក បដាចំនួន ៨០សន្លឹក ស្មើ ៥០សាលា។

- **ខេត្តឧត្តរមានជ័យ៖** មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានផ្សព្វផ្សាយអប់រំ ដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្ស តាមរយៈការចែកខិតប័ណ្ណ ១.៣២៧សន្លឹក។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ១៩៣.៨២៨នាក់(ស្រី ៨៦.៥២៦នាក់) អនីតិជន ៣.១២៣នាក់ (ស្រី ១.១៥៣នាក់)៖
  - ស្របច្បាប់ ១៥១.១៦១នាក់(ស្រី ៦៩.៦៦៥នាក់) អនីតិជន ៤២២នាក់(ស្រី ១៥២នាក់)។
  - មិនស្របច្បាប់ ៤១.៩៩៣នាក់(ស្រី ១៦.៥៧៣នាក់)អនីតិជន២.៥៧១នាក់(ស្រី ៩៦៦នាក់)។
  - ដាច់ការទាក់ទង ៦៧៤នាក់(ស្រី ២៨៨នាក់) អនីតិជន ១៣០នាក់(ស្រី ៣៥នាក់)។
- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១៩.២០៨នាក់(ស្រី ៧.៨៦៥នាក់) អនីតិជន ២៦២នាក់(ស្រី ៩៥នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត បានធ្វើការងារបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅក្រៅប្រទេសដោយខុសច្បាប់ ចំនួន ៣១លើក មនុស្សចំនួន ៤៧៦នាក់ (ស្រី ១៦២នាក់)៖
  - ខេត្តបន្ទាយមានជ័យ ៣០លើក មនុស្ស ៤៧១នាក់ (ស្រី ១៦០នាក់)
  - ខេត្តព្រះវិហារ ០១លើក មនុស្ស ០៥នាក់ (ស្រី ០២នាក់)។

### ២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- អគ្គស្នងការដ្ឋាននគរបាលជាតិ

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ និងខេត្តកែប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន ២៥៨គោលដៅ មនុស្សចំនួន ១.៣៨៤នាក់ (ស្រី ១.០០៧នាក់)។

• កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង កំពត កោះកុង ក្រចេះ ព្រះវិហារ និងខេត្តតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ៣៣លើក។

**២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

▪ ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ២៣៧នាក់(ស្រី ២២នាក់) មាន១៧សញ្ជាតិ រួមមាន៖ ចិន ១០៩នាក់(ស្រី ០១នាក់) កូរ៉េខាងត្បូង ៥៦នាក់ (ស្រី ០៨នាក់) អាមេរិក ៤១នាក់ (ស្រី ១០នាក់) អូស្ត្រាលី ០៧នាក់(ស្រី ០២នាក់) បារាំង ០៦នាក់ ជប៉ុន ០៤នាក់ វៀតណាម ០៣នាក់ ឥណ្ឌូនេស៊ី ០២នាក់ កាណាដា ០១នាក់(ស្រី) ម៉ាឡេស៊ី ០១នាក់ អាឡឺម៉ង់ ០១នាក់ ហ្វីលីពីន ០១នាក់ ថៃ ០១នាក់ អ៊ីស្រាអែល ០១នាក់ ឆែក ០១នាក់ អាហ្វ្រិកខាងត្បូង ០១នាក់ និង ម៉ារ៉ុក ០១នាក់។ បានវាយតម្លៃបញ្ជូនឱ្យក្រុមការងារច្រកចេញ-ចូលតែមួយចំនួន ២១៤នាក់ (ស្រី ២៤នាក់)។

**៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

• **ខេត្តព្រះសីហនុ៖** ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន ១.១៣៣នាក់។

• **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះស្រង់ទិន្នន័យ និងបានកំណត់ទីតាំងសិប្បកម្មផលិតឥដ្ឋ ក្នុងស្រុកគោលដៅចំនួន០២ គឺនៅស្រុកវ៉ារិន និងស្រុកបន្ទាយស្រីសរុបចំនួន ០៥សិប្បកម្ម ដែលមានកម្មករចំនួន ២២១នាក់ (ស្រី ១១៣នាក់)។

• **ខេត្តប៉ៃលិន៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ច ដើម្បីទប់ស្កាត់ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មនៅឡឥដ្ឋចំនួន ០៣កន្លែង។

• **ខេត្តបន្ទាយមានជ័យ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើបច្ចុប្បន្នភាពនៅសិប្បកម្មផលិតឥដ្ឋ ស្ថិតក្នុងឃុំទឹកជោ ស្រុកព្រះនេត្រព្រះ ចំនួនពីរកន្លែង មានកម្មករនិយោជិតបម្រើការងារ ចំនួន ១១នាក់ (ស្រី ០៥នាក់) និងកុមារអាយុក្រោម១៥ឆ្នាំ រស់នៅជាមួយគ្រួសារ ០៦នាក់ (ស្រី០៣នាក់)។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

**គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ២១ករណី លើ១៩ករណី កើនឡើងចំនួន ០២ករណី ស្មើនឹង ១០,៥២% ៖

• ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្តចំនួន ២៥នាក់ (ស្រី ០២នាក់)។
• សង្គ្រោះជនរងគ្រោះចំនួន ៥១នាក់ (ស្រី ៣១នាក់) អាយុក្រោម១៥ឆ្នាំ ១៥នាក់ អាយុ១៥-១៧ឆ្នាំ ០៤នាក់ និងអាយុ១៨ឆ្នាំឡើង ៣២នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ១០នាក់ ប្រគល់ឱ្យអន្តោប្រវេសន៍ ២២នាក់ និងប្រគល់ឱ្យគ្រួសារ ១៩នាក់) ក្នុងនោះចែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៦ករណី/០១ករណី (កើនឡើង ០៥ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៨នាក់។ សង្គ្រោះជនរងគ្រោះចំនួន ២៨នាក់ អាយុក្រោម១៥ឆ្នាំ ០២នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ២៥នាក់ (ប្រគល់ឱ្យអន្តោប្រវេសន៍ ២២នាក់ និងប្រគល់ឱ្យគ្រួសារ ០៦នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០២ | ០៦ | ០៣ |
| -អំពើលក់ដូរមនុស្ស | ០១ | ០២ | ០១ |
| -អំពើនាំឆ្លងដែន | ០២ | ១៤ | ០២ |
| -ការទទួលយកមនុស្សដោយមានគោលដៅ | ០១ | ០៦ | ០២ |
| *សរុប* | *០៦ ករណី* | *២៨ នាក់* | *០៨ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១៥ករណី/១៨ករណី (ថយចុះ ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៧នាក់ (ស្រី ០២នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ២៣នាក់ អាយុក្រោម១៥ឆ្នាំ ១៣នាក់ អាយុ១៥-១៧ឆ្នាំ ០៣នាក់ និងអាយុ១៨ឆ្នាំឡើង ០៧នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ១០នាក់ និងប្រគល់ឱ្យគ្រួសារ ១៣នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ១០ | ០២ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០០ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១១ | ១១ | ១២ |
| -អំពើអាសប្រធាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០២ | ០២ |
| *សរុប* | *១៥ ករណី* | *២៣ នាក់* | *១៧ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា
  - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសចិនចំនួន ១០នាក់ (ស្រី០៩នាក់ កុមារី ០១នាក់) ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ។
  - មណ្ឌលសំចតប៉ោយប៉ែតៈ
    - ទទួលពលករចំណាកស្រុក ដែលបញ្ជូនត្រឡប់ពីប្រទេសថៃចំនួន៦៤៧នាក់ (ស្ត្រី ២២៧នាក់) កុមារ ៧៩នាក់ (កុមារី ៣៥នាក់) បានកំណត់អត្តសញ្ញាណបឋមរកឃើញករណីងាយរងគ្រោះ ០៥នាក់ (ស្ត្រី ០១នាក់)។

- ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សតាមរយៈធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃចំនួន ១០នាក់ (កុមារា ០៦នាក់ កុមារី ០៤នាក់)។

❖ <u>ដោយឡែក</u>៖

- ការទទួលជនរងគ្រោះពីសមត្ថកិច្ចក្នុងស្រុកចំនួន ២១នាក់ (ស្ត្រី ០២នាក់) ជនជាតិចិន ១៤នាក់ និងវៀតណាម ០៧នាក់ (ស្ត្រី ០២នាក់)។
- ការបញ្ជូនរងគ្រោះដោយការជួញដូរកម្លាំងពលកម្មចំនួន ១៧នាក់ (ស្ត្រី ០៤នាក់) ឥណ្ឌា ០៨នាក់ (ស្ត្រី ០១នាក់) វៀតណាម ០៨នាក់ (ស្ត្រី ០៣នាក់) និងឥណ្ឌូនេស៊ី ០១នាក់។

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

• នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួលជនរងគ្រោះដែលវិលត្រឡប់ពីក្រៅប្រទេសចំនួន ២១នាក់ អនីតិជន ០២នាក់ លទ្ធផលសម្ភាសន៍ រកឃើញដូចខាងក្រោម៖

- ប្រទេសចិនចំនួន ១៩នាក់ (រងគ្រោះដោយអាពាហ៍ពិពាហ៍ឆ្មុយពីធន្ធៈ ០៨នាក់ នាំទៅធ្វើការដោយខុសច្បាប់ ០៧នាក់ និងស្នាក់នៅដោយខុសច្បាប់ ០៤នាក់)។
- ប្រទេសវៀតណាមចំនួន ០១នាក់ (រងគ្រោះនាំទៅធ្វើការនៅចិនដោយខុសច្បាប់)។
- ប្រទេសម៉ាឡេស៊ីចំនួន ០១នាក់ (រងគ្រោះនាំទៅធ្វើការដោយខុសច្បាប់)។

• កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃ និងវៀតណាម បញ្ជូនត្រឡប់មកវិញចំនួន ៣៨លើក មនុស្សចំនួន ៥៥៤នាក់ (ស្រី ១៩៨នាក់) អនីតិជន ៦៣នាក់ (ស្រី ២៩នាក់) ក្នុងនោះមាន៖

- ខេត្តបន្ទាយមានជ័យចំនួន ៣៣លើក មនុស្ស ៥៤១នាក់ (ស្រី ១៩៤នាក់) អនីតិជន ៦៣នាក់ (ស្រី ២៩នាក់)។
- ខេត្តស្វាយរៀងចំនួន ០១លើក មនុស្ស ០១នាក់ (ស្រី ០១នាក់)។
- ខេត្តកោះកុងចំនួន ០៤លើក មនុស្ស ១២នាក់ (ស្រី ០៣នាក់)។

### ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ៣១នាក់ (ស្ត្រី ១១នាក់ កុមារី ០១នាក់) ក្នុងនោះ៖ អង្គការការពារសិទ្ធិកុមារ/កុមារីតាស់កម្ពុជា ២១នាក់ (ស្ត្រី ០២នាក់) អង្គការមូលនិធិហាការអន្តរជាតិ ០៦នាក់(ស្ត្រី) អង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ ០២នាក់ (ស្ត្រី ០១នាក់ កុមារី ០១នាក់) និងអង្គការមូលនិធិ A21 ០២នាក់(ស្ត្រី)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្រី |
|---|---|---|---|---|
| ១ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយអង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា រៀបចំវគ្គបណ្តុះបណ្តាលបន្តថ្នាក់ឃុំនូវគោលការណ៍ណែនាំ ស្តីពីការទប់ស្កាត់ ការពារ និងឆ្លើយតបដោយអំពើជួញ | ០១ | ៤៥ | |

| | | | | |
|---|---|---|---|---|
| | ជួរមនុស្ស ដើម្បីផ្តល់សេវាសមស្របដល់មន្ត្រីនិងជនបង្គោលថ្នាក់ស្រុក និងឃុំ ក្នុងស្រុកស្ទោង ខេត្តកំពង់ធំ។ | | | |
| ២ | **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដោយមានការឧបត្ថម្ភគាំទ្រដោយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ៖<br>-សហការរៀបចំដោយលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តពោធិ៍សាត់<br>-សហការរៀបចំដោយលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបន្ទាយមានជ័យ | <br><br><br><br>០១<br>០១ | <br><br><br><br>៥០<br>៣២ | <br><br><br><br>៣៦<br>២៦ |
| ៣ | **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានសហការជាមួយអង្គការមេត្រីអន្តរជាតិ(AIM SWAT) បើកវគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធវិធីប្រតិបត្តិការ ដល់មន្ត្រីជំនាញនាយកដ្ឋាន។ | ០១ | ២០ | ០២ |
| ៤ | **ខេត្តកំពង់ធំ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការបញ្រ្ជាបយេនឌ័រ ក្នុងការបង្កើនការអង់អាចដល់ស្ត្រី និងអំពើហិង្សាក្នុងគ្រួសារ ដល់ គ.ក.ន.ក គ.ក.ស.ក និងនាយប៉ុស្តិ៍នគរបាល រដ្ឋបាលឃុំ។ | ០១ | ៤០ | ២៣ |
| ៥ | **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន០៦ បើកវគ្គបណ្តុះបណ្តាលដោយបានបញ្ជ្រាបការយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារធាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អដើម្បីបង្កើនផលិតភាពផលិតផលច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋម។ | ១៥ | ២៨១ | ១១៨ |
| ៦ | **ខេត្តបន្ទាយមានជ័យ៖** មន្ទីរកិច្ចការនារីខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការរំលោភសេពសន្ថវៈ នៅភូមិវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ។ | ០១ | ៤៣ | ២៧ |
| | សរុប | ២១ លើក | ៥០៦ នាក់ | ២៣២ នាក់ |

### ក.២. សិក្ខាសាលា

- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំសិក្ខាសាលា ស្តីពីការរៀបចំផែនការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ (២០២៤-២០២៨) ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ប្រធាន អនុប្រធាននាយកដ្ឋាន ក្រសួង ស្ថាប័ន គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធ អភិបាលរងទទួលផែន រាជធានី-ខេត្ត ស្នងការរងទទួលផែនរាជធានី-ខេត្ត អង្គការដៃគូ និងមន្ត្រីបច្ចេកទេស សរុបចំនួន **១៧១**នាក់ (ស្រី **៧៩**នាក់)។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងដំណើរពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

ខ.១.១ កិច្ចប្រជុំក្នុងប្រទេស

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

• បានរៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីការគ្រប់គ្រងលំហូរពលកររទេសន្តប្រវេសន៍ ឆ្លងកាត់ព្រំដែន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី គណៈកម្មាធិការចំពោះកិច្ចដោះស្រាយបញ្ហាពលករតាមព្រំដែន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ ជាសមាជិក គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អភិបាលរង អភិបាលខេត្តជាប់ព្រំដែនថៃ ឯកឧត្តមស្ថានអគ្គកុងស៊ុលរបស់ប្រទេសកម្ពុជាប្រចាំខេត្តស្រះកែវ ប្រធានសាលាដំបូងខេត្តបាត់ដំបង សងការខេត្តជាប់ព្រំដែនថៃ ប្រធានវរៈនគរបាលការពារព្រំដែនគោក ប្រធាន អនុប្រធានច្រកទ្វារព្រំដែន ប្រធានប៉ុស្តិ៍អន្តោប្រវេសន៍ តំណាងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត អភិបាល អភិបាលរងស្រុក នៃខេត្តជាប់ព្រំដែន និងមន្ត្រីពាក់ព័ន្ធ សរុបចំនួន ១៩៥នាក់ (ស្រី ២៥នាក់) នៅខេត្តបន្ទាយមានជ័យ។

• បានរៀបចំកិច្ចប្រជុំ ស្តីពីការកែសម្រួលគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ និងអង្គការ JICA តាមរយៈគម្រោងអភិវឌ្ឍសមាសភាពដើម្បីជួយដល់ជនរងគ្រោះដែលរួចពីការជួញដូរមនុស្ស។

### ខ.២. ទស្សនកិច្ច

• លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំមន្ត្រីជាន់ខ្ពស់នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ធ្វើទស្សនកិច្ចនៅមណ្ឌលទទួលពលករកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង ដំណើរទស្សនកិច្ចក៏បានធ្វើការសំណេះសំណាលជាមួយក្រុមការងារ នៃមណ្ឌលទទួលពលករកំរៀង ព្រមទាំងមន្ត្រីសាលាស្រុកកំរៀង នគរបាលនៃអធិការដ្ឋាននគរបាលស្រុកកំរៀង អាវុធហត្ថស្រុកកំរៀង កម្លាំងការពារព្រំដែនគោក និងមន្ត្រីនៃការិយាល័យការងារស្រុកកំរៀង។

### ខ.៣. ការទទួលជួបពិភាក្សាការងារ

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

• លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានទទួលជួបជាមួយតំណាងអង្គការ អាស៊ានអាក់ ក្នុងគោលបំណងធ្វើបទបង្ហាញ ស្តីពីផែនការសកម្មភាពការងាររបស់អង្គការអាស៊ានអាក់ ក្នុងកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

• លោកជំទាវឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ អមដោយលោកជំទាវឧត្តមសេនីយ៍ទោ រ៉ែន **សិរីលក្ខិណា** អគ្គលេខាធិការរង បានផ្តល់កិច្ចសម្ភាសន៍ដល់តំណាង Jica ក្នុងគោលបំណងកែសម្រួលសៀវភៅគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

• **ខេត្តកំពង់ឆ្នាំង៖** លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៣៤២៦លើក មានអ្នកចូលរួមសរុប ៦២៨នាក់ (ស្រី ១២៥នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ១០លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០១លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន ១៥លើក។(ឧបសម្ព័ន្ធ១)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក. ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

- បើកវគ្គបណ្ដុះបណ្ដាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្ដីសម្រេច ស្ដីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្ដេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមីនា ឆ្នាំ ២០២៤

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងារ របស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៨. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

៩. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១០. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.........ខែ.........ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ.........ឆ្នាំ២០២៤

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ ( សរុបចំនួន ២៦លើក) មនុស្សចំនួន ៤២៨នាក់ (ស្រី ១២៥នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួមសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១១ច្បាប់ លិខិតចូល ២២ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១០ច្បាប់ លិខិតចូល ១២ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រៀងរាល់កិច្ចប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែកុម្ភៈ ឆ្នាំ២០២៣ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ប្រចាំខែកុម្ភៈ ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន៥០ច្បាប់ ។<br>- អាប់ឡូតរូបភាពសកម្មភាព គ ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ.ប.ខ.ជ និង គ.ប.ជ.Wiki បានចំនួន ០៥សកម្មភាព។<br>- អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ១៣ច្បាប់។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>- លោកប្រធានក្រុម បានចូលរួមជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅសាលាខេត្តពោធិ៍សាត់។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការជំរុញឱ្យទទួលបានសេវាគាំទ្រ សម្រាប់ជនរងគ្រោះ នៃអាពាហ៍ពិពាហ៍ដោយបង្ខំ នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ និងវគ្គបណ្តុះបណ្តាល ស្តីពីចំណាកស្រុកដោយសុវត្ថិភាព និងប្រឆាំងការជួញដូរមនុស្ស នៅខេត្តពោធិ៍សាត់។ |

| | |
|---|---|
| | - លោកប្រធានក្រុម បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីកិច្ចសហការក្នុងការប្រមូល និងផ្តល់ពត៌មានសេវាពាក់ព័ន្ធ សម្រាប់កសាងប្រព័ន្ធគ្រប់គ្រងករណីសេវាសង្គមកិច្ចរួមគ្នា នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ និងកិច្ចប្រជុំពិភាក្សា ស្តីពីការរៀបចំផែនការឆ្នាំ២០២៤ លើបញ្ហាសុខភាពជនទេសន្តរប្រវេសន៍។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>- លោកជំទាវ អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការពិនិត្យតាមដាននិងការរាយការណ៍ ដំណាក់កាលទី២ រៀបចំឡើងដោយកម្មវិធីអាស៊ានអូស្ត្រាលី-ដើម្បីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ និងវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តពោធិ៍សាត់ និងបន្ទាយមានជ័យ។<br>- លោកអនុប្រធានក្រុម បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីកិច្ចសហការក្នុងការប្រមូល និងផ្តល់ព័តមានសេវាពាក់ព័ន្ធ សម្រាប់កសាងប្រព័ន្ធគ្រប់គ្រងករណីសេវាសង្គមកិច្ចរួមគ្នា នៅសណ្ឋាគារភ្នំពេញ។<br>- លោកស្រីអនុប្រធានក្រុម បានចូលរួមពិធីដាក់ឱ្យដំណើរការគម្រោងទេសន្តរប្រវេសន៍ ធុរកិច្ច និងសិទ្ធិមនុស្ស (MBHR)នៅតំបន់អាស៊ី លើកកម្ពស់ទំនួលខុសត្រូវសាជីវកម្ម និងសិទ្ធិពលករទេសន្តរប្រវេសន៍ ក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ជាសកល តាមប្រព័ន្ធ Video Conference នៅទីក្រុងបាងកក។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>○ លោកអនុប្រធានក្រុម បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - បានរៀបចំកិច្ចប្រជុំ ស្តីពីការកែសម្រួលគោលការណ៍ណែនាំ ស្តីពីបែបបទនិងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៥លើក អ្នកចូលរួមសរុបចំនួន ៤២៨នាក់ (ស្រី ១២៥នាក់)** | |
| ខេត្តកណ្តាល | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែកុម្ភៈ ចំនួន០១លើក អ្នកចូលរួមចំនួន៣៣នាក់ ស្រី២២នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែកុម្ភៈ ចំនួន០៤លើក អ្នកចូលរួមចំនួន១២៦នាក់ ស្រី០២នាក់។ |
| ខេត្តសៀមរាប | - ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំដើម្បីធ្វើការតាមដានត្រួតពិនិត្យ០៨លើក អ្នកចូលរួមចំនួន២២២នាក់ ស្រី៨០នាក់។ |
| | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំឆ្លងរបាយការណ៍ប្រចាំ២០២៣ ចំនួន០១លើក អ្នកចូលរួមចំនួន១៧នាក់ ស្រី០៦នាក់។ |
| ខេត្តកំពត | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែកុម្ភៈ ចំនួន០១លើក អ្នកចូលរួមចំនួន៣០នាក់ ស្រី១៥នាក់។ |